# កំណាព្យ

## ចំប៉ាជូនចិត្ត

បទសោរទិនវិសាល

ផ្កាសស្រស់ពៅសៀតលើកាណ៏[1]   គឺបុស្បា[2]ទេពឈ្មោះចំប៉ា
សមជាតិនឹងភ័ក្ត្រាអូនណ៎ា![3]   អប្សរាខ្វារដួងចិត្តបង។
ពៅជាចំប៉ាពិតប្ដីប៉ង   ស្រឡាញ់ញញឹមយកមកថ្នម
លើបង្គងដែលយើងក្រង   ទ្រនំមានទ្រព្យស្នេហ៏ក្សេមក្សាន្ត។
ថើបថ្ពាល់ពៅស្រូបក្លិនចំប៉ា   ពិដោរ[4]គ្មានផ្ទៀបនឹងនរណា
គឺមានតែមួយលើលោកា   ទេព្ធាកត់ត្រាជាស្រីង្គារ[5]។
ថើមកាយស្រមៃត្រងដម[6]ផ្កា   ពនិតា[7]នៅជាសង្សារ
ក្នុងភពនឹងថ្កល់ក្នុងចិន្ដា   ថៃដួងស្នេហាពីដំបូង។



ច្រើនវចនានុក្រមខ្មែររបស់ពុទ្ធសាសនាបណ្ឌិត្យ

---

[1] កាណ៏ ៖ ន. ត្រចៀក, សព្វថ្ងៃគេច្រើនប្រើជារាជសព្ទ ៖ ព្រះកាណ៏។
[2] បុស្បា ៖ ន. ផ្កាគ្រប់យ៉ាង។
[3] ណ៎ា! ៖ ពាក្យសំរាប់បញ្ជាក់សេចក្ដីឱ្យប្រាកដ ៖ ដូចជាសួរថែមថា ‹‹ មិនមែនឬ ? ››។
[4] ពិដោរ ៖ ក្លិនក្រអូប។
[5] ស្រីង្គារ (អាន ស្រឹង គា) ៖ ន. គ្រឿងប្រលោមចិត្ត, សេចក្ដីស្រឡាញ់។
[66] ដម ៖ ន. ទឹកថ្លាដែលកើតនៅក្នុងផ្កា ‹‹គ្រឿងក្រអូប›, ច្រើននិយាយទឹកដម។
[7] ពនិតា ៖ (អាន ពន់និតា ឬ ពៈនិតា) ភរិយា។